# ២០ឆ្នាំធ្វើការពង្រឹងសង្គមស៊ីវិលនៅកម្ពុជា៖ ដល់ពេលត្រូវបូកសរុបឡើងវិញ

## សេចក្តីផ្តើម

បន្ទាប់ពីមានកិច្ចប្រឹងប្រែងជាអន្តរជាតិអស់ជាង ២០ឆ្នាំ ដើម្បីពង្រីកការយល់ដឹងអំពី សិទ្ធិផ្នែកសេដ្ឋកិច្ច សង្គម និង វប្បធម៌មក មានសំណួរសំខាន់មួយផុសឡើងថា តើកម្ពុជាសម្រេចបានហើយឬនៅ នូវសង្គមស៊ីវិលមួយដ៏រឹងមាំ និងរួបរួមគ្នា? ការពិចារណាដោយយកចិត្តទុកដាក់លើសំណួរនេះ នាំឲ្យមានការពិភាក្សាប្រកបដោយគំនិតល្អិតល្អន់ ដែលមិនទាន់មានចម្លើយច្បាស់លាស់ទេ។ សង្គមស៊ីវិលនៅកម្រិតជាតិ នៅទន់ខ្សោយនៅឡើយ ប៉ុន្តែសង្គមស៊ីវិលដ៏ស្វាហាប់មួយហាក់កំពុងផុសឡើងពីស្រទាប់មហាជន។

ការពិភាក្សាលើសំណួរនេះ ជាដំបូងបំភ្លឺលើចំណុចខ្វែងមតិដ៏សំខាន់ថា តើអង្គការមិនមែនរដ្ឋាភិបាល (NGO) និងសង្គមស៊ីវិល ធាតុពិតវាដូចគ្នាឬយ៉ាងណា ហើយបន្ទាប់មកកំណត់ពីគោលគំនិតនៃសង្គមស៊ីវិលកម្ពុជា។ តមកទៀតមានការពិនិត្យជាទូទៅលើ NGOs ដោយកំណត់ពី NGOs ដែលបានចូលរួមនានា, អ្នកណាខ្លះគាំទ្រពួកគេ និងហេតុអ្វី។ ចំណុចចុងក្រោយ គឺការពិនិត្យពីការវិវត្តនៃ NGOs ក្នុង២ទសវត្សរ៍កន្លងទៅ ដោយផ្តោតថា តើ NGOs ជាសង្គមស៊ីវិលមែនឬទេ និង តើ NGOs បានជួយលើកស្ទួយសង្គមស៊ីវិលដល់កម្រិតណា ព្រមទាំងផ្តោតលើចលនានាពេលថ្មីៗ ក្នុងការពង្រាយ NGOs ទៅដល់ស្ទើរគ្រប់កន្លែងនៅកម្ពុជា នៅក្នុងសង្គមស៊ីវិលកម្រិតមូលដ្ឋាន។

## តើ NGOs និងសង្គមស៊ីវិលធាតុពិត គឺដូចគ្នាឬយ៉ាងណា?

ទោះបីជាពាក្យ សង្គមស៊ីវិល ឃើញមានប្រើយ៉ាងទូលំទូលាយក្តី ក៏និយមន័យនៅមិនទាន់កំណត់ច្បាស់លាស់ទេ។ អ្នកបកស្រាយនានាបានសន្និដ្ឋានថា អត្ថន័យនៃពាក្យនេះនៅស្រពិចស្រពិល និងពិបាកកំណត់បានក្នុងការពិតជាក់ស្តែង។ និយមន័យបែបទូលាយ និងមានលើកឡើងជាទូទៅមួយដែលសហគមន៍ផ្តល់ជំនួយនៅកម្ពុជា និងប្រទេសផ្សេងទៀត គាំទ្រឲ្យប្រើ បានកំណត់សង្គមស៊ីវិលថាជា "មជ្ឈដ្ឋានអន្តរការីមួយនៅចន្លោះរវាងរដ្ឋ នឹងគ្រួសារ ហើយរួមមានអង្គការនានាដែលដាច់ដោយឡែកពីរដ្ឋ មានស្វ័យភាពដាច់ពីរដ្ឋ និងបង្កើតឡើងតាមការស្ម័គ្រចិត្តដោយសមាជិកសង្គម ដើម្បីការពារ ឬពង្រឹងផលប្រយោជន៍ ឬតម្លៃសីលធម៌របស់ខ្លួន" (White 1994, 337-338)។ និយមន័យនេះ សង្កត់ធ្ងន់លើចំណុចសំខាន់ៗមួយចំនួន។ ទី១ សង្គមស៊ីវិល ជាការប្រមូលផ្តុំគ្នានូវអង្គការផ្សេងៗនៅក្នុងក្របខ័ណ្ឌនៃសមាគមស្ម័គ្រចិត្តស្វយ័ត។ ទី២ ក្របខ័ណ្ឌនេះ ការពារផលប្រយោជន៍ជាសមូហភាពរបស់អង្គការ។ ទី៣ ក្របខ័ណ្ឌនេះ តំណាងឲ្យសកម្មភាពផ្ទាល់ និងដោយស្ម័គ្រចិត្តនានា នៅពេលមានការបញ្ចេញមតិផ្ទាល់ខ្លួនផុសផុលឡើង និងមានមនុស្សកាន់តែច្រើនមករួបរួមគ្នា ដើម្បីសម្រេចវត្ថុបំណងដ៏ជាក់លាក់ផ្សេងៗ ជាពិសេសក្នុងការទាមទារឲ្យរដ្ឋឆ្លើយតបនឹងវត្ថុបំណងរបស់ខ្លួន។ ចំណុចមួយដែលគួរបញ្ជាក់បន្ថែម គឺនិយមន័យនេះ ឆ្លុះបញ្ចាំងពីរចនាសម្ព័ន្ធជាទូទៅ និងលក្ខណៈសំគាល់ជាធម្មតានៃសង្គមស៊ីវិលនៅបស្ចិមប្រទេស។

តើកម្ពុជាមានទម្រង់ផ្ទាល់ខ្លួនមួយ នៃសង្គមស៊ីវិលឬទេ? សង្គមស៊ីវិល ពិតជាមាននៅកម្ពុជា ប៉ុន្តែវាខុសប្លែកពីទម្រង់នៅបស្ចិមប្រទេស។ តាំងពីមុនពេលផ្ទុះសង្គ្រាមម្លេះ May Ebihara (1968) បានវែកញែកថា សង្គមស៊ីវិលកម្ពុជាមិនមែនជាអង្គភាពមានអង្គការចាត់តាំង ដែលតភ្ជាប់ខ្លួនទៅនឹងរដ្ឋនោះទេ ប៉ុន្តែវាស្តែងចេញតាមទម្រង់ផ្សេងៗ នៃការដោះដូរគ្នានៅក្នុងសង្គម ឬភាពផ្តល់ឲ្យគ្នាទៅវិញទៅមក ដែលរងឥទ្ធិពលពី និងទ្រទ្រង់ដោយបណ្តាញនៃសាច់ញាតិ និងការរាប់អានគ្នា។ បើពិនិត្យឲ្យល្អិតល្អន់ សង្គមស៊ីវិលកម្ពុជា ប្រមូលផ្តុំសំខាន់នៅលើវត្ត និងក្រុមរួមសមាគមគ្នាផ្សេងៗ ដែលបំពេញតួនាទីភាគច្រើនខាងសាសនា សង្គម និងការអភិវឌ្ឍ ជាជាងផ្តោតលើភាពជាតំណាង (ផ្នែកនយោបាយ) ជាសមូហភាព និងការបញ្ចេញមតិរបស់ក្រុមចំណាប់អារម្មណ៍ និងចលនាសង្គមផ្សេងៗ ទៅដល់រដ្ឋ ដើម្បីដោះស្រាយនូវបញ្ហាដែលជាក្តីបារម្ភ។

ក្នុងកិច្ចប្រឹងប្រែងផ្តល់សិទ្ធិអំណាច ដល់សង្គមស៊ីវិលកម្ពុជា ពួកអ្នកផ្តល់ជំនួយនៅបស្ចិមប្រទេស បានជួយទ្រទ្រង់ដល់ NGOs នៅកម្ពុជាតាំងពីដើមទសវត្សរ៍ ១៩៩០ មកម្លេះ។ នៅពេលនោះ គេរំពឹងថា អាចពង្រឹងសង្គមស៊ីវិលនៅកម្ពុជា ឲ្យវិវត្តឡើងលើសពីទំនាក់ទំនងក្នុងសង្គមជនជាតិដើមបែបបុរាណ ដើម្បីដើរតួនាទីកាន់តែសំខាន់ក្នុងការកែតម្រូវនូវតុល្យភាពអំណាច ដែលអាចជួយលើកកម្ពស់អភិបាលកិច្ចល្អទៀតផង។ តួនាទីដ៏សំខាន់មួយទៀតរបស់ NGOs គឺ ផ្តល់នូវសេវាសង្គមដ៏ចាំបាច់នានាដែលវិស័យសាធារណៈពុំមានផ្តល់ឲ្យ ដោយសាររដ្ឋមានសមត្ថភាពនៅខ្សោយ។

ពាក្យ NGO ក៏មានន័យមិនសូវច្បាស់លាស់ ស្រដៀងគ្នានឹងពាក្យសង្គមស៊ីវិលដែរ។ Clarke (1998, 2-3) បានកំណត់និយមន័យ NGOs ថាជា "...អង្គការឯកជន មិនស្វែងរកចំណេញ និងមានជំនាញវិជ្ជាជីវៈ ដែលមានលក្ខណៈសំគាល់ដាច់ដោយឡែកតាមផ្លូវច្បាប់ និងមានគោលដៅផ្តោតលើសុខុមាលភាពសាធារណៈ"។ NGOs គឺជាអង្គការមានជំនាញវិជ្ជាជីវៈដែលកកើតឡើងជាសំខាន់ដើម្បីធ្វើជា "មធ្យោបាយ" ឬ "ភ្នាក់ងារ"

---

អត្ថបទនេះ រៀបរៀងដោយ អ៊ូ ស៊ីវហួច អ្នកស្រាវជ្រាវនៃវិទ្យាស្ថាន CDRI ដោយផ្អែកលើឯកសារ Ou and Kim (2013)។ សូមយោងអត្ថបទនេះថា Ou Sivhuoch and Kim Sedara. 2014. "20 Years' Strengthening of Cambodian Civil Society: Time for Reflection." *Cambodia Development Review* 18(3):10-13. Phnom Penh: CDRI.

ជួយសម្រេចនូវគោលដៅសាធារណៈនានា និងផ្តល់សិទ្ធិអំណាចដល់សង្គមស៊ីវិលក្នុងការអភិវឌ្ឍប្រទេស (Clarke 1998)។ តួនាទីរបស់ NGOs ធ្វើជាមធ្យោបាយជួយសម្រេចនូវគោលដៅរបស់អ្នកផ្សេង វាបង្ហាញជាស្រេចថា NGOs មានលក្ខណៈខុសគ្នាពីនិយមន័យទូទៅនៃសង្គមស៊ីវិល ព្រោះសង្គមស៊ីវិលត្រូវបានបង្កើតឡើង ដើម្បីបានជាប្រយោជន៍ដល់សមាជិកខ្លួន។ លក្ខណៈដែល NGOs ខ្វះខាតទំនាក់ទំនងក្នុងស្រទាប់មហាជន ឬមូលដ្ឋានគាំទ្ររបស់ប្រជាជន និងត្រូវមានគណនេយ្យភាពឡើងលើចំពោះម្ចាស់ជំនួយបែបនេះ វាបង្ហាញថែមទៀតថា NGOs មិនមែនជាសង្គមស៊ីវិលឡើយ។

ជំរឿនលើកក្រោយបំផុតក្នុងឆ្នាំ២០១២ បង្ហាញថា អង្គការសង្គមស៊ីវិលកំពុងដំណើរការនៅកម្ពុជា មានសរុប ១៣១៥ ក្នុងនេះមាន ១១៣០ (៨៦%) ទទួលបានជំនួយជាមូលនិធិ (CCC 2013, 7)។ បាតុភូតថ្មីមួយទៀតនៅកម្ពុជា គឺ សង្គមស៊ីវិលកូនកាត់ ដែលសំដៅលើ NGOs ថ្នាក់ក្រោមជាតិ និងអង្គការសហគមន៍ (community-based organizations - CBOs) ដែលមានចំនួនប្រមាណ ២៥.០០០។ អង្គការទាំងនោះ ត្រូវបានចាត់ទុកជាសង្គមស៊ីវិលកូនកាត់ ដោយសារវាបម្រើព្រមគ្នានូវផលប្រយោជន៍របស់ប្រជាជនក្នុងមូលដ្ឋាន, របស់រដ្ឋ និងរបស់បរទេស។ អង្គភាពសង្គមស៊ីវិលទាំងនេះ ជារឿយៗគេបង្កើតឡើង ដើម្បីបម្រើផលប្រយោជន៍របស់ ប្រជាជនមូលដ្ឋាន ហើយតាមធម្មតាតែងទទួលបានជំនួយទ្រទ្រង់ ពី NGOs។

> *“NGOs ខ្លះមានអំពើពុករលួយ និងខ្លះទៀតខ្វះអភិបាលកិច្ចល្អ និងតម្លាភាព។ NGOs ដែលបង្កើតឡើងក្នុងគោលដៅចម្បងស្វែងរកប្រាក់ចំណេញ ក៏មានច្រើនដែរ៖ 'NGOs មួយចំនួន នៅតែមានបង្កើតឡើង ដើម្បីផ្តល់ការងារ ជាជាងជួយដល់ជនក្រីក្រ'”*

## តើ NGOs បានពង្រឹងសង្គមស៊ីវិលដល់កម្រិតណា?

នៅថ្នាក់ជាតិ ជាពិសេសនៅទសវត្សរ៍១៩៩០ ម្ចាស់ជំនួយតែងផ្តល់មូលនិធិ ដល់ក្រុម NGOs ជាក់លាក់មួយ ដែលភាគច្រើនជាអង្គការធំៗមានសក្តានុពលខ្លាំង និងប្រវត្តិការងារល្អ ជាជាងផ្តល់ជំនួយដល់ក្រុមសង្គមស៊ីវិលជាទូទៅ ដូចជា សហជីពជាដើម ដើម្បីធានាឲ្យមានលទ្ធផលដូចការរំពឹងទុក អាចវាស់វែងបាន និងបញ្ជាក់នូវភាពត្រឹមត្រូវនៃការផ្តល់ជំនួយគាំទ្រ។ អ្នកសិក្សាស្រាវជ្រាវមួយចំនួនវែកញែកថា ការសម្រេចចិត្តផ្តល់មូលនិធិរបស់ម្ចាស់ជំនួយ ផ្តល់ផលប្រយោជន៍មិនបានល្អទេដល់សកម្មភាពរួមគ្នាដើម្បីលើកកម្ពស់ស្ថានភាពសង្គម ហើយ Hughes (2009) បានហៅបាតុភូតនេះថា "យុទ្ធសាស្ត្របំបែកល្អិតៗ" របស់ម្ចាស់ជំនួយ។ Christie (2013, 91) ក៏យល់ស្របដែរថា "...ក្នុងន័យនយោបាយ ការជំរុញសង្គមស៊ីវិលបន្តផ្តោតលើការបង្កើត NGOs ជាជាងបណ្តាសមាគមមានទម្រង់ទូលំទូលាយជាងនេះ" ប៉ុន្តែការសិក្សាជាក់ស្តែង ដោយគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា បានកំណត់គណនេយ្យភាពទៅថ្នាក់លើរបស់ NGOs ថាជាបញ្ហាដ៏សំខាន់មួយ៖ "ការអនុវត្តគណនេយ្យភាព ជាទូទៅមានទិសពីក្រោមទៅលើ... ដោយសារ NGOs ភាគច្រើន ត្រូវពឹងផ្អែកលើម្ចាស់ជំនួយ ហេតុនេះគេអាចរំពឹងបានថា ការសម្រេចចិត្តរបស់អង្គការ ត្រូវរងឥទ្ធិពលយ៉ាងខ្លាំងពីម្ចាស់ជំនួយ/ដៃគូអភិវឌ្ឍន៍នានា។ ក្នុងការកំណត់គោលដៅជាយុទ្ធសាស្ត្រ ... ការគិតគូរពីអាទិភាព ឬបញ្ហាចោទក្នុងសហគមន៍ វាស្ថិតនៅលំដាប់ទី២ គឺនៅក្រោយរបៀបវារៈ និងអាទិភាពរបស់ ម្ចាស់ជំនួយ" (CCC.2010, 31-32)។

កម្មវិធីជំនួយផ្តោតលើលទ្ធផលរបស់ម្ចាស់ជំនួយ ភាគច្រើនផ្តល់អាទិភាពលើការបង្ហើយគម្រោង និងមិនសូវបានផ្តោតទៅលើឥទ្ធិពលរបស់វាទេ (R.F. Catalla and T. Catalla 2001) កុំថាឡើយដល់ជួយពង្រឹងសង្គមស៊ីវិលជាទូទៅ។ ដូច្នេះ NGOs មានទំនាក់ទំនងតិចណាស់ជាមួយថ្នាក់មូលដ្ឋាន ឬស្រទាប់ប្រជាជន ហើយទុកឲ្យប្រជាជនមូលដ្ឋាននៅតែរប៉ាត់រប៉ាយគ្មានការរៀបចំ និងគ្មានសិទ្ធិអំណាច។ សរុបមក NGOs ផ្តល់ការងារមានប្រាក់កម្រៃខ្ពស់ដល់ អ្នកស្រទាប់លើមានការអប់រំល្អនៅតាមទីក្រុង ដែលចំណាយពេលធ្វើការងារនៅឯរាជធានី និងទីក្រុងធំៗច្រើនជាងខិតខំតភ្ជាប់ទំនាក់ទំនង ជាមួយប្រជាជនមូលដ្ឋាន។ NGOs ខ្លះមានអំពើពុករលួយ និងខ្លះទៀតខ្វះអភិបាលកិច្ចល្អ និងតម្លាភាព។ NGOs ដែលបង្កើតឡើងក្នុងគោលដៅចម្បងស្វែងរកប្រាក់ចំណេញ ក៏មានច្រើនដែរ៖ "NGOs មួយចំនួន នៅតែមានបង្កើតឡើង ដើម្បីផ្តល់ការងារ ជាជាងជួយដល់ជនក្រីក្រ" (Nowaczyk 2009, 25)។ កង្វះគោលការណ៍ប្រជាធិបតេយ្យ របស់អង្គការនានា បានធ្វើឲ្យចុះខ្សោយដល់ ភាពគួរឲ្យជឿទុកចិត្ត និងប្រសិទ្ធភាពរបស់ពួកគេ ក្នុងការលើកកម្ពស់អង្គការ និងចលនាផ្សេងៗរបស់សង្គមស៊ីវិលជាទូទៅ។

ទោះបី NGOs ដើមឡើយបានប្រមូលផ្តុំគ្នានៅក្នុងរាជធានី និងទីក្រុងធំៗ ហើយនិន្នាការនេះ នៅតែបន្តទៅមុខ និងបង្កឧបសគ្គជាក់ស្តែង ដែលរារាំងដល់ប្រតិបត្តិការរបស់ពួកគេ ក៏មានបាតុភូតថ្មីមួយកំពុងផុសឡើងជាបណ្តើរៗ។ នៅថ្នាក់មូលដ្ឋានចាប់ពីពាក់កណ្តាលទសវត្សរ៍២០០០ មក NGOs បានរីកសាយទៅដល់តំបន់ជនបទ ហើយអង្គការសហគមន៍ (CBO) ដែលជារឿយៗមាន NGOs ជួយទ្រទ្រង់ផង បានកកើតឡើងនៅស្ទើរគ្រប់ភូមិ។ អ្នកបកស្រាយ បានហៅព្រឹត្តិការណ៍នេះថាជាបាតុភូតកូនកាត់ (សូមមើលដូចជា öjendal 2014 ជាដើម)។ បាតុភូត CBO នេះ បានកកើតឡើងដោយមានចោទបញ្ហាដូចជា ការក្តោបក្តាប់ដោយជនមានវណ្ណៈខ្ពស់ និងចីរភាពមិនសូវប្រាកដប្រជា ដោយសារមានការពឹងផ្អែកផ្នែកហិរញ្ញវត្ថុទៅលើ NGOs និងម្ចាស់ជំនួយ។ ទោះយ៉ាងនេះក្តី ចំណុចវិជ្ជមានខ្លះដែលមិនធ្លាប់មានពីមុនមក កំពុងលេចរូបរាងបន្តិចម្តងៗ៖ កម្ពុជាភាវូបនីយកម្មនៃសង្គមស៊ីវិល (ពោលគឺ អ្នកចាប់អារម្មណ៍បានផ្លាស់ប្តូរពីជនបរទេស មកជាប្រជាជនក្នុងស្រុកវិញ) និងការផុស

ឡើងនៃស្ថាប័នអន្តរការី។ ការវិវត្តថ្មីៗទាំងនេះ នាំឲ្យមានក្រុមប្រភេទខ្លះកកើតឡើងយ៉ាងច្រើន ជាពិសេស ក្រុមសន្សំ (saving group) រាប់ពាន់ក្រុម៖ គ្រាន់តែអង្គការសេដាក (CEDAC) មួយ រាយការណ៍ថា បង្កើតបាន ៣០០០ក្រុមសន្សំ ដែលដំណើរការប្រកបដោយជោគជ័យ។ ក្រុមទាំងនេះ និងក្រុមដទៃទៀត បានផុសឡើងនៅទូទាំងប្រទេស ហើយវាជាបាតុភូតមួយមិនធ្លាប់មានសោះ ជួយញ៉ាំងឲ្យសង្គមស៊ីវិលទំនើបនៅកម្ពុជាលេចចេញជារូបរាង។

ករណីសិក្សាផ្នែកជាតិពន្ធសាស្ត្រលំអិតមួយ (Hiwasa 2014) បានវែកញែកថា កិច្ចប្រឹងប្រែងរបស់ម្ចាស់ជំនួយក្នុងការបង្កើតក្រុមសន្សំនៅតាមជនបទកម្ពុជា បានហុចលទ្ធផលដោយបង្កើតបាននូវក្រុមជាច្រើនដែលមានដំណើរការ និងជួយផ្តល់សិទ្ធិអំណាចផ្នែកសេដ្ឋកិច្ច និងសង្គមទៅដល់ប្រជាជនមូលដ្ឋាន ជាពិសេសស្ត្រី។ មុនពេលមានក្រុមសន្សំក្រៅផ្លូវការទាំងនេះ ស្ថានភាពស្ត្រីអាចប្រដូចទៅនឹង "កង្កែបនៅក្នុងអណ្តូង"។ សព្វថ្ងៃនេះ សកម្មភាពរួមគ្នារបស់ស្ត្រីតាមរយៈការចូលរួមក្នុងក្រុមសន្សំ បានជួយឲ្យពួកគេមានសមត្ថភាពអាចចូលរួមដោយផ្ទាល់ក្នុងវិស័យសាធារណៈ និងសង្គមស៊ីវិល។ ម្យ៉ាងទៀតក្រុមសន្សំរបស់ស្ត្រី បានក្លាយជាថ្នាលមួយ សម្រាប់ការកសាងបណ្តាញសង្គម និងបណ្តាញក្រុមដែលបានរីកដុះដាល ទៅដល់ថ្នាក់ស្រុក និងថ្នាក់ជាតិ ព្រមទាំងបានផ្តល់ជាវេទិកាមួយ សម្រាប់ឲ្យក្រុមស្ត្រី លើកបញ្ហាក់ពីក្តីបារម្ភរបស់ខ្លួន (Hiwasa 2014)។ ការសិក្សាមួយផ្សេងទៀត លើវិស័យមីក្រូហិរញ្ញវត្ថុ (Jörgensen 2009) បញ្ជាក់ថា ទោះជាកិច្ចប្រឹងប្រែងរបស់ម្ចាស់ជំនួយទទួលបរាជ័យ ក្នុងការជំរុញក្រុមសន្សំនៅមូលដ្ឋានក្តី ក៏វាបានបង្កើតនូវក្រុមមានជោគជ័យល្អជាច្រើន ដែលបានជួយបង្កើនមូលធនសង្គម និងជះឥទ្ធិពលវិជ្ជមានទៅលើដំណើរការផ្តល់សិទ្ធិអំណាច។ ការវាយតម្លៃពីគម្រោងលើកស្ទួយជីវភាពកសិករមួយ ទ្រទ្រង់ដោយអង្គការសេដាក បានបង្ហាញពីការរីករាលដាលយ៉ាងលឿន និងខ្លាំងក្លានៃក្រុមកសិករ, ក្រុមផលិតករ និងក្រុមសន្សំ ក្នុងនេះមាន "ការសិក្សាគេតែងយោងដល់ជាញឹកញាប់មួយ ស្តីពី ជីវភាពនៅទីជនបទកម្ពុជា ដែលមានចំណងជើងថា "នៅពេលគ្រប់គ្រួសារក្លាយជាកោះមួយ"។ សព្វថ្ងៃប្រជាកសិករនៅស្រុកត្រាំកក់កំពុងបង្ហាញថាចំណងជើងនេះ អាចក្លាយជាប្រវត្តិសាស្ត្រពិតបានលឿនប៉ុណ្ណា" (Johnsen and Prom 2005, 2)។

ឥទ្ធិពលវិជ្ជមាននៃការខិតខំរបស់សហគមន៍អន្តរជាតិ ក្នុងការកសាងសង្គមស៊ីវិលថ្នាក់មូលដ្ឋាននៅកម្ពុជា ត្រូវបានគេទទួលស្គាល់ ដោយសារ វា"... បានទទួលជោគជ័យក្នុងការលើកកម្ពស់សមត្ថភាពមូលដ្ឋាន និងឆន្ទៈក្នុងការរៀបចំ ... ដោយបានជ្រាបចូលទៅក្នុងសង្គមស៊ីវិលមួយភាគធំ" ហើយវាបានបង្កើតនូវបរិយាកាសល្អមួយសម្រាប់ "មជ្ឈដ្ឋានសមាគមអន្តរការី" (öjendal 2014, 35)។ ទោះបីមានគោលដៅចម្បងខាង ផ្នែកសេដ្ឋកិច្ចក្តី ក៏ CBOs មានអំណាចជាសមូហភាពខាងនយោបាយដែរ (Feuer 2014)។ ការវិភាគនាពេលថ្មីៗអំពី យុទ្ធសាស្ត្រអភិវឌ្ឍន៍សហគមន៍របស់ CEDAC តាមការបង្កើតសមាគមកសិករ បង្ហាញថា នៅកម្រិតមូលដ្ឋាន ផលិតករមួយក្រុមមានសមាជិកត្រឹមតែ ១០គ្រួសារ ក៏អាចគ្រប់គ្រាន់ សម្រាប់កេណ្ឌប្រមូលសកម្មភាពក្នុងមូលដ្ឋាន ដើម្បីឆ្លើយតបនឹងការគំរាមកំហែង មិនថាក្នុងផ្នែកបរិស្ថាន (ឧ. ទឹកជំនន់, ជំងឺឆ្លងរាលដាល) ឬផ្នែកនយោបាយ (ឧ. ការរំលោភយកដីធ្លី, ឈ្មួញកេញប្រវ័ញ្ច ឬក៏អំពើពុករលួយ) នោះទេ (Feuer 2014, 246)។ នៅកម្រិតមូលដ្ឋាន ការផ្តល់សិទ្ធិអំណាចដល់ក្រុមប្រជាជននៅជនបទ ដូចជា សហព័ន្ធសមាគមកសិករកម្ពុជានៃផលិតករកសិកម្ម តាមរយៈការបង្កើនសមត្ថភាពសម្រាប់សកម្មភាពជារួម, បានផ្តល់ជាមធ្យោបាយដ៏សំខាន់សម្រាប់ឆ្លើយតបនឹង រដ្ឋាភិបាលដែលធ្វើការបំពេញអាសនៈ និងការគំរាមកំហែង៖ "នៅពេលដែលសមាគមកសិករ នៅតែរក្សាទំនាក់ទំនង ជាមិត្តភាពជាមួយរដ្ឋាភិបាលនោះ... វត្តមានអង្គការធំៗ នៅជនបទទាំងនេះ គឺជាបញ្ហាប្រឈមដំបូងមួយហើយ ចំពោះការក្តោបក្តាប់ផ្តាច់មុខ លើអំណាចរដ្ឋនៅទីជនបទ" (Feuer 2014, 246)។ ម្យ៉ាងទៀត ការរីកសាយនៃបណ្តាញ និងក្រុមសន្សំរបស់ ស្ត្រីនៅមូលដ្ឋាន អាចចូលរួមចំណែកក្នុងរយៈពេលវែង ដល់ការរីកធំធាត់នៃចលនាផ្សេងៗ ក្នុងស្រទាប់មហាជនដែល Feuer បានចង្អុលបង្ហាញនេះ។

*“មុនពេលមានក្រុមសន្សំក្រៅផ្លូវការទាំងនេះ ស្ថានភាពស្ត្រីអាចប្រដូចទៅនឹង 'កង្កែបនៅក្នុងអណ្តូង'។ សព្វថ្ងៃនេះ សកម្មភាពរួមគ្នារបស់ស្ត្រីតាមរយៈ ការចូលរួមក្នុងក្រុមសន្សំ បានជួយឲ្យពួកគេមានសមត្ថភាព អាចចូលរួមដោយផ្ទាល់ ក្នុងវិស័យសាធារណៈ និងសង្គមស៊ីវិល។”*

ករណីប្លែកពីគេមួយគឺ សហគមន៍ខ្មែរដើម្បីអភិវឌ្ឍន៍កសិកម្ម (KCAD) ដែលជាអង្គការមិនមែនរដ្ឋាភិបាលថ្នាក់ខេត្តមួយបានកកើតឡើង ២០ឆ្នាំមកហើយ នៅខេត្តកំពត។[១] KCAD តំណាងឲ្យអង្គការសង្គមស៊ីវិលដ៏ពិតៗ ដែលមិនអាចផុសឡើងដោយគ្មានការទ្រទ្រង់ពីម្ចាស់ជំនួយឡើយ។ ក្នុងដំណាក់កាលដំបូងដ៏គ្រោះថ្នាក់ KCAD ត្រូវពឹងផ្អែកលើជំនួយទ្រទ្រង់ពីខាងក្រៅ ប៉ុន្តែក្រោយមកអាចបង្កើតប្រាក់ចំណូលដោយខ្លួនឯង ទោះបីមិនបានទៀងទាត់ក្តី តាមការរៀបចំវគ្គបណ្តុះបណ្តាលអ្នកប្រើប្រាស់បរិក្ខារកសិកម្ម។ KCAD បំពេញបានតាមនិយមន័យសង្គមស៊ីវិល ដោយសារមានស្វ័យភាពដែលបានអនុញ្ញាតឲ្យ

---

[១] ករណីផ្សេងទៀតប្រហែលកើតមាននៅតំបន់ផ្សេង ប៉ុន្តែវាស្ថិតនៅក្រៅវិសាលភាពនៃការអង្កេតសម្រាប់ការសិក្សា។

អង្គការនេះ អាចវាតដែនអនុវត្តសកម្មភាព និងបំពេញបានតាមគោលដៅរបស់ខ្លួន ក្នុងមជ្ឈដ្ឋានសង្គមស៊ីវិល។ ក្រោយពីបានរឹងមាំហើយ KCAD បានបន្តប្រតិបត្តិការខ្លួនដោយឯករាជ្យពីរដ្ឋាភិបាល។ នាយករបស់ សហគមន៍ខ្មែរដើម្បីអភិវឌ្ឍន៍កសិកម្ម (KCAD) រកចិញ្ចឹមជីវិតខ្លួនឯងតាមមធ្យោបាយផ្សេង ប៉ុន្តែអាចបំពេញគោលបំណងផ្នែកមនុស្សធម៌របស់គាត់បាន តាមការចូលរួមធ្វើការមិនពេញម៉ោងក្នុងសកម្មភាពរបស់អង្គការ។ ករណីប្លែកមួយទៀតគឺ អង្គការមិនមែនរដ្ឋាបាល (NGOs) ដូចជា អង្គការ Hagar និង Friends International បានវិវត្តប្រែក្លាយខ្លួនទៅជាអាជីវកម្មបម្រើសង្គម ដែលអាចឲ្យពួកគេបង្កើតប្រាក់ចំណូលប្រកបដោយចីរភាព និងជាទូទៅប្រកាន់ខ្ជាប់បានតាមរបៀបវារៈរបស់ខ្លួន ក្នុងការជួយដល់ក្រុមទន់ខ្សោយ ដូចជា សិស្ស/និស្សិតក្រីក្រ និងកុមារកំព្រា ជាដើម។ ប៉ុន្តែច្បាស់ហើយ ការផ្លាស់ប្ដូរពីអង្គការមិនមែនរដ្ឋាភិបាល ទៅជាអាជីវកម្មបម្រើសង្គម (នេះជាទម្រង់កូនកាត់មួយទៀតនៃសង្គមស៊ីវិល) មិនអាចកើតឡើងបានទេ បើសិនគ្មានជំនួយទ្រទ្រង់ពីដំបូង អំពីម្ចាស់ជំនួយខាងក្រៅ។

## សេចក្ដីសន្និដ្ឋាន

កិច្ចប្រឹងប្រែងរបស់ម្ចាស់ជំនួយ ក្នុងការពង្រឹងសង្គមស៊ីវិលនៅកម្ពុជាកន្លងមក បានផ្ដល់លទ្ធផលចម្រុះ។ នៅថ្នាក់ជាតិ អង្គការមិនមែនរដ្ឋាភិបាល ជាពិសេសកាលពីដំបូងៗ សើងតែមិនបានជួយពង្រឹង សិទ្ធិអំណាចរបស់សង្គមស៊ីវិលសោះទេ ដោយសារមានបញ្ហាប្រឈមចម្បងពីរ។ ទី១ ម្ចាស់ជំនួយខាងក្រៅដែលទាមទារគណនេយ្យភាពទៅថ្នាក់លើផង និងគណនេយ្យភាពប្រភេទជាក់លាក់ខ្លះទៀតផង បានផ្ដល់មូលនិធិប្រមូលផ្ដុំទៅលើអង្គការមួយក្រុមតូច ហើយធ្វើឲ្យអង្គការមិនមែនរដ្ឋាភិបាល (NGOs) មិនបានផ្សារភ្ជាប់ល្អទៅនឹងអាទិភាពរបស់អ្នកទទួលផលនៅតាមមូលដ្ឋាន ដែលខ្លួនត្រូវបម្រើ។ ទី២ បញ្ហានៅក្នុងអង្គការមិនមែនរដ្ឋាភិបាលខ្លួនឯង បានធ្វើឲ្យខូចខាតដល់ភាពគួរឲ្យជឿជាក់ និងប្រសិទ្ធភាពរបស់អង្គការ។ បើទោះបីឧបសគ្គទាំងនេះ នឹងមិនងាយរលាយបាត់ ដោយសារ អង្គការមិនមែនរដ្ឋាភិបាល នៅពឹងផ្អែកខ្លាំងលើជំនួយពីខាងក្រៅក្ដី ក៏ការងាររបស់ពួកគេកាន់តែរីកដុះដាលទៅដល់ តំបន់ជនបទច្រើនឡើង ហើយជាបណ្ដើរៗ បានឈានទៅតភ្ជាប់ជាមួយប្រជាជនមូលដ្ឋាន។ ចាប់តាំងពីពាក់កណ្ដាលទសវត្សរ៍២០០០មក អង្គការមិនមែនរដ្ឋាភិបាល កាន់តែច្រើនឡើង បានពង្រីកសកម្មភាពគម្រោងរបស់ខ្លួនទៅដល់ជនបទ ដោយបង្កើតបាននូវក្រុមសង្គមស៊ីវិលកូនកាត់ជាច្រើន ជាពិសេសក្រុមសន្សំ។ និន្នាការគួរឲ្យពេញចិត្តទាំងនេះ ផ្ដល់ក្ដីសង្ឃឹមថា សង្គមស៊ីវិលនៅថ្នាក់ទាបបំផុត ពិតជាមានសក្ដានុពលដើម្បីរីកលូតលាស់ និងមានផលប្រយោជន៍ដាច់ដោយឡែកមួយខាងផ្នែកនយោបាយ។

## ឯកសារយោង


Catalla, R.F., and T. Catalla 2001.*Cambodia: A Situation Analysis.* Bangkok: Action Aid-Asia.

CCC, Cooperation Committee for Cambodia. 2010. *Reflections, Challenges, and Choices: 2010 Review of NGO Sector in Cambodia.* Phnom Penh: CCC.

CCC. 2013. *CSO Contributions to the Development of Cambodia 2012: Opportunities and Challenges.* Phnom Penh:CCC.

Christie, R. 2013. *Peacebuilding and NGOs: State-Civil Society Interactions*. London: Routledge.

Clarke, G. 1998. *The Politics of NGOs in South-East Asia: Participation and Protest in the Philippines*. London: Routledge.

Ebihara, M. 1968. "Svay, a Khmer Village in Cambodia.*"* PhD dissertation, Columbia University.

Feuer, H. 2014. "Competitive Discourses in Civil Society: Pluralism in Cambodia's Agricultural Development Platform." In *Southeast Asia and the Civil Society Gaze: Scoping a Contested Concept in Cambodia and Vietnam,* edited by G. Waibel, J. Ehlert and H.N. Feuer. London: Routledge.

Hiwasa, A. 2014. "Changing Gendered Boundaries in Rural Cambodia." In *Southeast Asia and the Civil Society Gaze: Scoping a Contested Concept in Cambodia and Vietnam,* edited by G. Waibel, J. Ehlert and H.N. Feuer. London: Routledge.

Hughes, C. 2009. *Dependent Communities: Aid and Politics in Cambodia and East Timor*. New York: Cornnell Southeast Asia Program.

Johnsen, S., and T. Prom. 2005. *Evaluation, ILFARM (Improving Livelihoods of Subsistence Farmers) Project, Tram Kok District, Takeo Province, Cambodia.* Phnom Penh: JICA.

Jörgensen, J.N.I. 2009. "Revisiting Social Capital in Development: Can Group-Based Microfinance Reproduce Social Capital? A Case Study in Rural Cambodia.*"* Master's thesis, Lund University.

Nowaczyk, M. 2009. "Between a Rock and a Hard Place: Organizations and Institutionalized Corruption in Cambodia." MSc Thesis, University of Birmingham.

Öjendal, J. 2014. "In Search of a Civil Society: Re-negotiating State-Society Relations in Cambodia." In *Southeast Asia and the Civil Society Gaze: Scoping a Contested Concept in Cambodia and Vietnam*, edited by G. Waibel, J. Ehlert and H.N. Feuer. London: Routledge.

Öjendal, J., and Kim S. 2013. "Reconstruction and Local Democratization in Cambodia? An Empirical Review of the Potential of a Decentralization Reform." In *The Imperative of Good Local Governance: State of the Art of Local Governance and the Challenges for the Next Decade*,edited by J. Öjendal and A. Dellnäs. Tokyo: United Nations University Press.

Ou Sivhuoch and Kim Sedara. 2013. *20 Years' Strengthening of Cambodian Civil Society: Time for Reflection.* Working Paper Series No. 85. Phnom Penh: CDRI.

White, G. 1994. "Civil Society, Democratization and Development (I): Clearing the Analytical Ground."*Democratization* 1(3): 375-390.